COVID smart measures for schools

Information for families

# វិធានការឆ្លាតវៃ COVID សម្រាប់សាលារៀន

## ព័ត៌មានសម្រាប់ក្រុមគ្រួសារ

យើងដឹងថាការនៅជាមួយគ្នាក្នុងថ្នាក់រៀន គឺជាអ្វីដ៏ល្អបំផុតសម្រាប់ការរៀនសូត្រ ការលូតលាស់ និងសុខុមាលភាពរបស់សិស្សយើង។ នៅត្រីមាសនេះ យើងនឹងបន្តអនុវត្តវិធានការមួយចំនួន ដើម្បីអនុញ្ញាតឱ្យយើងផ្តល់អាទិភាពទាំងសុខុមាលភាពរបស់សិស្សយើង និងបរិយាកាសថ្នាក់រៀនដែលមិនផ្លាស់ប្តូរ និងប្រកបដោយផលិតភាព។

### ស្នាក់នៅផ្ទះប្រសិនបើមិនស្រួលខ្លួន

- ប្រសិនបើកូនរបស់អ្នកមិនស្រួលខ្លួនទេ អ្នកត្រូវតែរក្សាពួកគេនៅផ្ទះ។ ប្រសិនបើពួកគេបង្ហាញរោគសញ្ញា COVID-19 ពួកគេគួរតែធ្វើតេស្ត COVID-19 (PCR ឬ RAT) ហើយធ្វើតាមដំបូន្មានពីរដ្ឋាភិបាល NSW ស្តីពីការគ្រប់គ្រង COVID-19 ដោយសុវត្ថិភាពនៅផ្ទះ (managing COVID-19 safely at home)។
- កូនរបស់អ្នកគួរត្រឡប់ទៅសាលារៀនវិញ នៅពេលពួកគេមិនមានរោគសញ្ញាប៉ុណ្ណោះ។

### ការចាក់វ៉ាក់សាំង

- ការចាក់វ៉ាក់សាំងសម្រាប់ COVID-19 និងជំងឺបង្កឡើងដោយមេរោគផ្សេងទៀត គឺជាមធ្យោបាយដ៏ល្អបំផុតមួយក្នុងកិច្ចការពារខ្លួនអ្នក ក្រុមគ្រួសារ និងសហគមន៍របស់អ្នក។ ការចាក់វ៉ាក់សាំងគឺជាមធ្យោបាយមួយដែលមានសុវត្ថិភាព និងមានប្រសិទ្ធភាពក្នុងការផ្តល់ឱ្យប្រព័ន្ធភាពស៊ាំរបស់អ្នកជួយប្រឆាំងនឹងជំងឺជាច្រើន។
- សិស្ស និងបុគ្គលិកដែលមានសិទ្ធិទាំងអស់ ត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំង ឱ្យរក្សាបច្ចុប្បន្នភាពជាមួយនឹងការចាក់វ៉ាក់សាំងរបស់ពួកគេ ដើម្បីការពារសុខភាពរបស់ពួកគេ។
- បុគ្គលិកទាំងអស់ដែលធ្វើការនៅសាលារៀនសម្រាប់គោលបំណងជាក់លាក់ (schools for specific purposes (SSPs)) ត្រូវបានតម្រូវឱ្យចាក់វ៉ាក់សាំងពីរដងប្រឆាំងនឹង COVID-19 ឬមានការលើកលែងដែលមានសុពលភាពពីការប្រើថ្នាំ ឬការព្យាបាលណាមួយបន្តទៀតដែលនឹងនាំឱ្យមានគ្រោះថ្នាក់ផ្នែកវេជ្ជសាស្ត្រ។

### ការធ្វើតេស្តអង់ទីហ្សែនរហ័ស

- ការធ្វើតេស្តអង់ទីហ្សែនរហ័ស (Rapid antigen tests (RATs)) គួរតែបានប្រើប្រាស់ ប្រសិនបើកូនរបស់អ្នកកំពុងបង្ហាញរោគសញ្ញា COVID-19។
- សិស្សដែលធ្វើតេស្តវិជ្ជមាន COVID-19 ត្រូវបានលើកទឹកចិត្តឱ្យជូនដំណឹងដល់សាលារៀនរបស់ពួកគេ និងចុះបញ្ជីលទ្ធផលតេស្តវិជ្ជមានរបស់ពួកគេជាមួយ Service NSW ដើម្បីទទួលបានដំបូន្មាន និងការគាំទ្រទាន់ពេលពី ក្រសួងសុខាភិបាលរដ្ឋ NSW។
- សាលារៀននឹងរក្សាស្តុកនៃកញ្ចប់ធ្វើតេស្តអង់ទីហ្សែនរហ័ស នៅតាមទីតាំងសាលារៀន សម្រាប់គោលបំណងការធ្វើតេស្តតាមដានក្នុងករណីមានការផ្ទុះឡើងនៃជំងឺ។

### អនាម័យ និងការសម្អាត

- សិស្សត្រូវបានលើកទឹកចិត្តឱ្យលាងដៃរបស់ពួកគេជាប្រចាំជាមួយសាប៊ូ និងទឹក ហើយប្រើប្រាស់ឧបករណ៍ការពារផ្ទាល់ខ្លួនតាមតម្រូវការ។
- ការបង្កើនថ្ងៃសម្អាតសាលារៀន នឹងផ្តោតលើតំបន់ដែលប៉ះពាល់ច្រើន និងផ្ទៃរឹងផ្សេងទៀត ដៃទ្វារ ទូមានសោ កុងតាក់បិទបើកភ្លើង និងបង្កាន់ដៃនៅតាមជណ្តើរ និងតំបន់មានមនុស្សឡើងចុះ។

### ខ្យល់ចេញចូល

- ខ្យល់អាកាសបរិសុទ្ធ គឺជាទម្រង់នៃការដាក់ឱ្យមានខ្យល់ចេញចូលដែលមានប្រសិទ្ធភាពបំផុត ដើម្បីកាត់បន្ថយហានិភ័យនៃការឆ្លងមេរោគ។
- ក្នុងអំឡុងខែដែលក្តៅជាង ម៉ាស៊ីនត្រជាក់នឹងត្រូវបានប្រើប្រាស់ រួមជាមួយនឹងវិធីដាក់ឱ្យមានខ្យល់ចេញចូលនានា ដើម្បីធ្វើឱ្យមានតុល្យភាពរវាងកំដៅប្រកបដោយផាសុខភាព។
- កន្លែងរៀនសូត្រទាំងអស់នៅសាលារៀនរដ្ឋត្រូវបានត្រួតពិនិត្យ ដើម្បីធានាបាននូវកម្រិតសមស្របនៃខ្យល់ចេញចូល និងម៉ាស៊ីនបន្សុទ្ធខ្យល់ត្រូវបានផ្តល់តាមតម្រូវការ។
- ការប្រើប្រាស់ទីធ្លាក្រៅអគារនឹងត្រូវបានបន្តលើកទឹកចិត្ត ប្រសិនបើអាចធ្វើទៅបាន។

## ម៉ាស់

- ការពាក់ម៉ាស់ត្រូវបានលើកទឹកចិត្តយ៉ាងខ្លាំង នៅកន្លែងណាដែលអាចធ្វើទៅបានសម្រាប់សិស្ស បុគ្គលិក និងភ្ញៀវទាំងអស់ ជាពិសេសនៅក្នុងអគារ និង/ឬនៅពេលដែលការរក្សាគម្លាតរាងកាយមិនអាចធ្វើទៅបាន ហើយប្រសិនបើពួកគេត្រូវបានប៉ះពាល់នឹង COVID-19។
- ការពាក់ម៉ាស់ត្រូវបានបន្តទាមទារឱ្យមានគ្រប់ពេលវេលាសម្រាប់បុគ្គលិក អ្នកស្ម័គ្រចិត្ត និងអ្នកធ្វើការផ្សេងទៀតដែលគាំទ្រសិស្សរបស់យើង ដែលមានហានិភ័យខ្ពស់នៃជំងឺធ្ងន់ធ្ងរ ប្រសិនបើពួកគេឆ្លង COVID-19 មិនថាពួកគេនៅក្នុងសាលារៀនសម្រាប់គោលបំណងជាក់លាក់ អង្គភាពគាំទ្រ ឬថ្នាក់រៀនទូទៅឡើយ។

## ភ្ញៀវ

- ភ្ញៀវអាចចូលមកទីតាំងសាលារៀនទូទៅភាគច្រើន ដោយមិនគិតពីស្ថានភាពនៃការចាក់វ៉ាក់សាំងរបស់ពួកគេទេ។
- ភ្ញៀវដែលកំពុងចូលរួមដោយផ្ទាល់ជាមួយសិស្ស នៅកន្លែងដែលមានហានិភ័យខ្ពស់មួយចំនួនសម្រាប់ប្រតិបត្តិការរបស់សាលារៀន និងការផ្តល់កម្មវិធីសិក្សា និងដៃគូសម្ព័ន្ធសុខភាពសម្រាប់សុខុមាលភាពសិស្ស អាចត្រូវបានតម្រូវឱ្យពាក់ម៉ាស់។

## សកម្មភាព

- ការវាយតម្លៃហានិភ័យសុខភាព និងសុវត្ថិភាព នឹងត្រូវបានដាក់បញ្ចូលទៅក្នុងសកម្មភាពរៀបចំផែនការ រួមទាំងដំណើរកម្សាន្ត និងការបោះជំរុំពេញមួយយប់។
- ឪពុកម្តាយ និងអ្នកថែទាំនឹងត្រូវបានប្រាប់ឱ្យដឹងអំពីហានិភ័យនៃការប៉ះពាល់ ហើយនឹងត្រូវផ្តល់ការអនុញ្ញាតសម្រាប់សកម្មភាពជាក់លាក់នានា។

## ការឆ្លើយតបទៅនឹងស្ថានភាពក្នុងតំបន់

- សាលារៀននឹងធ្វើការជាមួយក្រុមការងារគ្រប់គ្រងករណីសុខភាព សុវត្ថិភាព និងសុខុមាលភាពបុគ្គលិករបស់ក្រសួង ដើម្បីឆ្លើយតបយ៉ាងសមស្របទៅនឹងស្ថានភាពក្នុងតំបន់ រួមទាំងការផ្ទុះឡើងនៃជំងឺបង្កឡើងដោយវីរុសផងដែរ។
- ក្នុងករណីខ្លះ សាលារៀនអាចណែនាំជាបណ្តោះអាសន្ននូវវិធានការបន្ថែម សម្រាប់រយៈពេលកំណត់ដើម្បីជួយបញ្ឈប់ខ្សែសង្វាក់នៃការឆ្លង រួមទាំងការតម្រូវឱ្យពាក់ម៉ាស់ ការពន្យារពេល ឬការកំណត់សកម្មភាពដែលមិនសំខាន់ចាំបាច់ និងការដឹកនាំក្រុមជាក់លាក់នានាឱ្យរៀនសូត្រពីចម្ងាយ។

## ការរៀនសូត្រពីចម្ងាយ

- សាលារៀនបន្តការចូលប្រើប្រាស់ឌីជីថល ធនធានរៀនសូត្រដែលបានបោះពុម្ព និងមានការណែនាំ ដើម្បីគាំទ្រសិស្សដែលត្រូវការរៀនសូត្រពីចម្ងាយ។

## សេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ

ប្រសិនបើអ្នកត្រូវការព័ត៌មានបន្ថែម សូមទូរសព្ទទៅនាយកសាលារបស់អ្នក។ ប្រសិនបើអ្នកត្រូវការអ្នកបកប្រែផ្ទាល់មាត់ ដើម្បីជួយអ្នកក្នុងការសាកសួររបស់អ្នក សូមទូរសព្ទទៅសេវាកម្មអ្នកបកប្រែផ្ទាល់មាត់តាមទូរសព្ទ តាមលេខ 131 450 ហើយស្នើសុំអ្នកបកប្រែផ្ទាល់មាត់ជាភាសារបស់អ្នក។ ប្រាប់ការីទូរសព្ទនូវលេខទូរសព្ទដែលអ្នកចង់ហៅ ហើយការីទូរសព្ទនឹងរៀបចំអ្នកបកប្រែផ្ទាល់មាត់ម្នាក់  ដើម្បីជួយអ្នកក្នុងការសន្ទនា។ អ្នកនឹងមិនត្រូវគេគិតថ្លៃសម្រាប់សេវាកម្មនេះទេ។

### រដ្ឋាភិបាលរដ្ឋញូវសៅវែល ប្តេជ្ញាធានាប្រតិបត្តិការរបស់សាលានៅតែបន្ត ខណៈពេលផ្តល់អាទិភាពដល់សុវត្ថិភាព និងសុខុមាលភាពរបស់សិស្ស និងបុគ្គលិកសាលា។